សួស្តី នៅក្នុងរូបភាពនេះ គឺនិយាយអំពីការធ្វើឲ្យបែកចាន។ ដោយចានយើងឃើញមានចានបាយ និងចានសម្ល ដែលអ្នកខ្លះគាត់ហៅថាចានគោម។

ដែលរូបភាពទី ១ យើងឃើញមានបុរសម្នាក់ដែលគាត់មានវ័យ ឬក៏អាយុប្រហែលជា ១៨ ឆ្នាំ។ គាត់ពាក់អាវយឺតពណ៌ស កមូល គាត់នៅក្នុងចង្ក្រានបាយ កំពុងតែចិតបន្លែដើម្បីធ្វើម្ហូបថ្ងៃនេះ។ អញ្ចឹងគាត់នៅក្នុងចង្ក្រានបាយ គាត់ឈរនៅខាងមុខតុ ដែលយើងឃើញនៅលើតុ យើងឃើញ នៅខាងលើតុ នៅក្បែរដៃខាងឆ្វេងរបស់គាត់ យើងឃើញមានបន្លែច្រើនប្រភេទ ដូចជាខ្ទឹមបារាំង ប៉េងប៉ោះ និងការ៉ុត ដែលប្រហែលជាគាត់ចង់ធ្វើស៊ុប ឬក៏សម្លសម្រាប់អាហារថ្ងៃនេះ។ អញ្ចឹងយើងឃើញគាត់កាន់កាំបិតនៅក្នុងដៃ កាំបិតតូចនៅក្នុងដៃខាងស្តាំរបស់គាត់ និងគាត់កាន់កាំបិតនោះដើម្បី គាត់ប្រើកាំបិតនោះដើម្បី ដើម្បីចិតបន្លែ ដើម្បីចិតបន្លែ។ ដែលគាត់កំពុងតែចិត ចិតការ៉ុតជាដុំតូចៗ។ អញ្ចឹងគាត់កំពុងតែចិតការ៉ុតជាដុំតូចៗ ប្រហែលជាគាត់ចង់ធ្វើ ចង់ធ្វើសម្ល ឬក៏ស៊ុបសម្រាប់អាហារថ្ងៃនេះ។ ដែលនៅ នៅលើតុដដែល នៅខាងស្តាំជិតដៃរបស់គាត់ យើងឃើញមានចានសម្ល យើងឃើញមានចានសម្ល ឬក៏ចានគោមមួយ ដែលគាត់ដាក់នៅក្បែរដៃរបស់គាត់។ អញ្ចឹងចាននោះប្រហែលជាគាត់ទុកប្រើសម្រាប់ នៅពេលដែលគាត់ចិតបន្លែជាដុំ ឬក៏ជាចំណិតតូចៗហើយ គាត់ដាក់បន្លែទាំងអស់នោះនៅក្នុងចានរបស់គាត់ ឬក៏ចាននោះគាត់ទុកនៅពេលដែលគាត់ចម្អិនម្ហូប ឬក៏គាត់ធ្វើសម្ល ឬក៏ស៊ុបរបស់គាត់ឆ្អិនហើយ គាត់អាចដួសស៊ុប ឬក៏សម្លនោះ ដាក់ចូលទៅក្នុងចានគោម ឬក៏ចានសម្លនោះ។ អញ្ចឹងគាត់ នៅខាង នៅខាងឆ្វេងដៃរបស់គាត់ គាត់ដាក់ គាត់ នៅខាងឆ្វេងដៃរបស់គាត់មានបន្លែ ខ្ទឹមបារាំង ប៉េងប៉ោះ ការ៉ុត នៅខាងស្តាំដៃរបស់គាត់គឺមានចានគោមមួយដែលដាក់ ដែលគាត់ដាក់នៅក្បែរនោះ។ អញ្ចឹងគាត់កំពុងតែហាន់បន្លែនោះជាដុំតូចៗ ជាដុំចំណិតតូចៗ ដោយប្រើកាំបិត។ អញ្ចឹងគាត់ ដោយប្រើកាំបិត និងគាត់នៅក្នុងផ្ទះបាយ គាត់នៅក្នុងផ្ទះបាយ។

រូបភាពទីពីរ នៅពេលដែលគាត់កំពុងតែ នៅពេលដែលគាត់កំពុងតែចិតការ៉ុតនោះជាដុំតូចៗ ចិតការ៉ុតនោះជាដុំតូចៗ ដោយសារតែគាត់ ដោយសារតែគាត់មិនបាន ដោយសារតែគាត់ភ្លេចខ្លួនថាគាត់បានទុកចានសម្ល និងចាន ចានសម្លឬក៏ចាន ចានសម្ល ឬក៏ចានគោម នៅក្បែរដៃខាងស្តាំរបស់គាត់ គាត់ក៏បានប៉ះដៃរបស់គាត់នៅពេលដែលចិត កំពុងតែចិតបន្លែការ៉ុតនោះ កែងដៃរបស់គាត់ក៏បានប៉ះ ក៏បានប៉ះចាននោះ ធ្វើឲ្យចាននោះដួលធ្លាក់ចុះទៅខាងក្រោម។ អញ្ចឹងធ្វើឲ្យគាត់មាន ធ្វើឲ្យគាត់ភ្ញាក់ ដោយសារតែគាត់មិនចង់ ដោយសារតែគាត់មិនចង់ឲ្យចាននោះដួលធ្លាក់ទៅខាងក្រោមទេ។ ប៉ុន្តែគាត់ភ្លេចខ្លួន ប៉ុន្តែគាត់ភ្លេចខ្លួន នៅពេលដែលគាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅពេលដែលគាត់កំពុងតែចិតការ៉ុតជាដុំតូចៗនោះ កែងដៃរបស់គាត់ក៏បានទៅប៉ះចានគោម ដែលទុកនៅក្បែរដៃរបស់គាត់នោះ។ អញ្ចឹងធ្វើឲ្យគាត់ ធ្វើឲ្យគាត់មានភាពភ្ញាក់ផ្អើល មានភាពភ្ញាក់ផ្អើល ដោយសារតែ ចានប្រសិនបើធ្លាក់ចុះទៅខាងក្រោម នឹងបែក។ អញ្ចឹងចានប្រសិនបើធ្លាក់ចុះទៅខាងក្រោមនឹងអាចបែកបាន ពីព្រោះនៅខាងក្រោមគឺជាឥដ្ឋ គឺជាឥដ្ឋ និងចានគឺជាចានថ្ម ដូច្នេះងាយស្រួលនៅពេលដែលទង្គិចគ្នា នៅពេលដែលធ្លាក់មួយទំហឹង គឺនឹងធ្វើឲ្យចាននោះបែកយ៉ាងងាយស្រួល។ អញ្ចឹងយើងឃើញគាត់នៅក្នុងផ្ទះបាយ ដៃ ដៃខាងឆ្វេងរបស់គាត់កាន់ការ៉ុត ដៃខាងស្តាំកាន់កូនកាំបិត ដោយគាត់កំពុងតែហាន់ការ៉ុតនោះ ដោយគាត់កំពុងតែហាន់ការ៉ុតនោះ ជាដុំតូចៗ ដោយគាត់ភ្លេចខ្លួន ក៏បានធ្វើឲ្យចានគោម ដែលដាក់ក្បែរ ដែលដាក់នៅក្បែរដៃរបស់គាត់ធ្លាក់ចុះទៅខាងក្រោម។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ ចាននោះក៏បានធ្លាក់ចុះមកខាងក្រោម ចាននោះក៏បានធ្លាក់ចុះមកក្រោម ធ្លាក់នៅលើឥដ្ឋ។

រូបភាពទី ៤ រូបភាពទី ៤ នៅពេលដែលចាននោះធ្លាក់មកដល់ឥដ្ឋ ចាននោះក៏បានបែក ក៏បានបែកខ្ចាយ ដែលធ្វើឲ្យចាននោះ យើងឃើញបែកជាចម្រៀកតូចៗ ជាចម្រៀកតូចៗ។ ដោយសារតែនៅក្នុង[...] ដោយសារតែផ្ទះរបស់គាត់គឺក្រាលដោយឥដ្ឋការ៉ូ ក្រាលដោយឥដ្ឋ ឬក៏ឥដ្ឋការ៉ូ ដូច្នេះ ចានគឺយើងធ្វើ ចាន ចានថ្ម អញ្ចឹងងាយស្រួលនៅពេលដែលធ្លាក់ចុះនិងប៉ះ នៅពេលដែលធ្លាក់មួយទំហឹងនៅលើឥដ្ឋ ចាននោះនឹងបែក ចាននោះនឹងបែក និងមិនអាចប្រើប្រាស់បានទៀតទេ។ អញ្ចឹងដោយសារតែយើង ជាក់ស្តែងយើងឃើញរូបភាពទីបួន ចាននោះធ្លាក់ចុះមកខាងក្រោម ធ្លាក់បែកជាបំណែក ឬក៏ជាចំណិត ឬក៏កម្ទេច កម្ទេចចានតូចៗ កម្ទេចតូចៗ អញ្ចឹងមិនអាចប្រើទៀតទេ មិនអាចប្រើបានទៀតទេ។

រូបភាពទី ៥ ដោយសារតែ ដោយសារតែគាត់គឺជាអ្នកធ្វើឲ្យបែកចាននោះ ដោយគាត់មិនបានប្រុងប្រយ័ត្ន អញ្ចឹងធ្វើឲ្យគាត់មានការ ធ្វើឲ្យគាត់មានការភ្ញាក់ផ្អើល ធ្វើឲ្យគាត់មានការភ្ញាក់ផ្អើលដោយសារតែគាត់ គាត់ភ្លេចខ្លួន ដោយគាត់បានដាក់ចាននោះនៅក្បែរដៃរបស់គាត់ ប៉ុន្តែគាត់ភ្លេចថាមានចាននៅក្បែរដៃរបស់គាត់។ អញ្ចឹងនៅពេលដែលគាត់មិនបានប្រុងប្រយ័ត្ន គាត់បានធ្វើឲ្យចាននោះធ្លាក់បែក ធ្វើឲ្យចាននោះធ្លាក់បែក។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពទីប្រាំនោះ យើងឃើញទឹកមុខរបស់គាត់ហាក់មាន ហាក់ដូចជាមានការសោកស្តាយ និងភ្ញាក់ផ្អើល ដោយសារតែនេះគឺជាអ្វីដែលគាត់មិន នេះគឺជាការមិនប្រុងប្រយ័ត្ន គឺជាការមិនប្រុងប្រយ័ត្ន ដោយធ្វើឲ្យចាននោះធ្លាក់ចុះមកខាងក្រោម។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងរូបភាពទី ៦ រូបភាពទី ៦ ក្រោយពេលដែលគាត់ធ្វើឲ្យចាននោះធ្លាក់បែក ធ្វើឲ្យចាននោះធ្លាក់បែកជាកម្ទេច ជាកម្ទេចតូចៗ គាត់ក៏បានដើរមកបន្ទប់សម្រាប់ដាក់អីវ៉ាន់ បន្ទប់ដាក់អីវ៉ាន់ដើម្បីសម្អាតផ្ទះ ដោយយើងឃើញនៅក្នុងបន្ទប់នោះយើងឃើញមាន យើងឃើញមាន ក្នុងបន្ទប់នោះយើងឃើញមានចំនួនបីថ្នាក់ ចំនួនបីថ្នាក់ ដោយថ្នាក់នីមួយៗគឺដាក់សម្រាប់ គឺដាក់សាប៊ូ ឬក៏ដាក់ ដាក់សាប៊ូ ឬក៏ទឹក ទឹកលាងកញ្ចក់ ទឹកលាងកញ្ចក់ ដែលប្រើសម្រាប់សម្អាតនៅក្នុងផ្ទះរបស់គាត់។ ដោយយើងឃើញផ្នែកខាងលើ នៅថ្នាក់ខាងលើ នៅថ្នាក់ខាងលើគេបង្អស់ យើងឃើញដូចជាមាន មាន មានដប មានដប ប្រហែលជាដបសាប៊ូ ប្រហែលជាដបសាប៊ូ និងដូចជាមានកន្សែងពោះគោនៅកន្លែងនោះផងដែរ និងថ្នាក់ទីពីរយើងឃើញមានដបជាច្រើន ប្រហែលជាដបសាប៊ូ ដបលាងចាន ឬក៏ទឹកសម្រាប់ជូតឥដ្ឋ ឬក៏ទឹកសម្រាប់ជូតកញ្ចក់នៅថ្នាក់ទីពីរ និងមានដូចជា មានអំបោស មានអំបោស មានអំបោសដង មាន មានអំបោសដងខ្លី មានអំបោស មានអំបោសដងខ្លី និងមានប្រដាប់សម្រាប់ចូកសំរាមដាក់ផ្អែកជាប់នឹងជញ្ជាំងនោះផងដែរ។ នៅថ្នាក់ខាងក្រោមយើងឃើញមានដប ដប និងមានធុងទឹកចំនួនពីរ ធុងទឹកចំនួនពីរ ដែលនៅថ្នាក់ខាងក្រោមនោះ នៅក្បែរនោះ នៅក្បែរនោះយើងឃើញមានម៉ាស៊ីនសម្រាប់បូមធូលី ឬក៏សម្រាប់បូមកម្ទេចតូចៗ និងមាន និងមានដូចជា និងមានដូចជាប្រដាប់ជូតឥដ្ឋ ប្រដាប់ជូតឥដ្ឋ និង និងប្រដាប់សម្រាប់ជូតកញ្ចក់ ឬក៏អំបោសដងវែងដែលដាក់ផ្អែកនៅក្បែរនោះផងដែរ។ អញ្ចឹងប្រហែលជា នោះគឺ[ជា] ប្រហែលជានៅជិតប្រដាប់ នៅជិតប្រដាប់ជូតឥដ្ឋនោះ ប្រហែលជាអំបោសដងវែង ឬក៏ប្រហែលជាប្រដាប់សម្រាប់ជូតកញ្ចក់ ប្រដាប់សម្រាប់ជូតកញ្ចក់ ដែលដាក់ផ្អែកនៅជាប់ទៅនឹងជញ្ជាំងនៅក្នុងបន្ទប់ដាក់អីវ៉ាន់នោះ។ អញ្ចឹងបុរសម្នាក់នោះគាត់ ក្រោយពេលដែលគាត់ធ្វើឲ្យបែកចាននៅក្នុង នៅក្នុងផ្ទះបាយ ឬក៏ចង្ក្រានបាយរបស់គាត់។ គាត់ក៏បានចូលមកក្នុងបន្ទប់ដាក់អីវ៉ាន់ ដើម្បីយកឧបករណ៍ ដើម្បីសម្អាត សម្អាតកម្ទេច ឬក៏អំបែងចានដែលបានធ្លាក់បែកនៅលើឥដ្ឋក្នុងបន្ទប់ ក្នុងផ្ទះបាយ ឬក៏ចង្ក្រានបាយរបស់គាត់។

រូបភាពទី ៧ រូបភាពទី ៧ គាត់ក៏បានយក គាត់ក៏បានយកអំបោសដងខ្លី អំបោសដងខ្លីជាមួយនឹងប្រដាប់ចូកសំរាម អញ្ចឹងគាត់យករបស់ទាំងពីរដើម្បី ដើម្បី ដើម្បីយកទៅបោសកម្ទេច ដើម្បីយកទៅបោសកម្ទេច និងប្រមូលកម្ទេចនោះ បោះចោលទៅខាងក្រៅ។ ពីព្រោះកម្ទេចចាន ប្រសិនបើយើងមិនបានប្រមូលឲ្យស្អាតទេ នៅពេលដែលយើងដើរអាចធ្វើឲ្យយើងមុតជើង អាចធ្វើឲ្យយើងមុតជើង និងអាចធ្វើឲ្យយើងមានរបួសបាន។ ដោយសារតែកម្ទេចចានគឺវាមុត វាមុតដូចជាកាំបិតអញ្ចឹង។ អញ្ចឹងប្រសិនបើយើងដើរដោយមិនបាន មិនបានពាក់ស្បែកជើង និងមិនបានប្រុងប្រយ័ត្នទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងអាចមុតជើងនឹងកម្ទេចចាននោះបានយ៉ាងងាយស្រួល។ អញ្ចឹងគាត់ត្រូវយក គាត់ត្រូវយកអំបោស និងប្រដាប់ចូកសំរាមនោះ ដើម្បីទៅប្រមូលកម្ទេចនោះឲ្យ ឲ្យស្អាត ឬក៏ដើម្បីប្រមូលឲ្យអស់ [...] ដើម្បីប្រមូលឲ្យអស់ពីលើឥដ្ឋ នៅក្នុងបន្ទប់ នៅក្នុងចង្ក្រានបាយ ឬក៏ផ្ទះបាយរបស់គាត់។ ដោយយើងឃើញនៅ នៅខាងមុខគាត់ យើងឃើញ នៅលើថ្នាក់នីមួយៗយើងឃើញដូចជាមានសាប៊ូ និងមានធុងទឹកនៅថ្នាក់ខាងក្រោម។

រូបភាពទី ៨ ក្រោយពេលដែលគាត់ដើរចូលទៅក្នុងបន្ទប់ដាក់អីវ៉ាន់ ដើម្បីយកអំបោសដងខ្លី និងជាមួយនឹងប្រដាប់ចូកសំរាម អញ្ចឹងគាត់ក៏បានយករបស់ទាំងពីរនោះ ដើរត្រលប់មកផ្ទះបាយវិញ ដើម្បីប្រមូលកម្ទេចចាន ដែលគាត់បានធ្វើឲ្យបែកដោយចៃដន្យ។ អញ្ចឹងគាត់ គាត់បានឱន គាត់បានឱនបោសកម្ទេចនោះ គាត់ប្រើអំបោសបោសកម្ទេចដែលមាននៅលើឥដ្ឋនោះ ដាក់ចូលទៅក្នុងប្រដាប់ចូកសំរាម ដើម្បី ដើម្បីយកវាចាក់ចោលទៅក្នុងធុងសំរាម។ អញ្ចឹងគាត់ គាត់ប្រមូលកម្ទេចនោះយ៉ាងប្រុងប្រយ័ត្ន ពីព្រោះប្រសិនបើមិនបានប្រមូលប្រុងប្រយ័ត្នទេ នៅពេលដែលយើងដើរមិនបានពាក់ស្បែកជើង យើងអាចមុតជើងបានដោយកម្ទេច ដោយកម្ទេចចាននោះដោយងាយ យ៉ាងងាយស្រួល ដោយសារតែកម្ទេចចាននៅពេលដែលបែក គឺវាមុតដូចជាកាំបិតអញ្ចឹងដែរ។ អញ្ចឹងគាត់បានបោសប្រមូល គាត់បានបោសប្រមូល ដោយប្រើ ដោយប្រើអំបោសដងខ្លី ប្រមូលចូលទៅក្នុងប្រដាប់ចូកសំរាម។

បន្ទាប់មកទៀតរូបភាពទី ៩ ក្រោយពេលដែលគាត់បោសប្រមូលស្អាតហើយ គាត់ក៏បានយកកម្ទេចនោះចាក់ចូលទៅក្នុងធុងសំរាម ចាក់ចូលទៅក្នុងធុងសំរាម។

បន្ទាប់មកទៀតរូបភាពទី ១០ គាត់ក៏បានដើរចូលមកក្នុងបន្ទប់ដាក់អីវ៉ាន់វិញ ដើម្បីយកអំបោស និង ដើម្បីយកអំបោស និងប្រដាប់ចូកសំរាមនោះដាក់ទៅកន្លែងដើមវិញ ដាក់ទៅកន្លែងដើមវិញ។ ដោយយើងឃើញនៅក្នុងបន្ទប់នោះ គឺយើងដាក់ គឺយើងដាក់ឧបករណ៍សម្រាប់បោសសម្អាតផ្ទះ សម្រាប់ជូតផ្ទះ និងសាប៊ូជាច្រើន និងធុងទឹកគឺយើងដាក់នៅក្នុងបន្ទប់នោះ អញ្ចឹងយើងហៅថាបន្ទប់ដាក់អីវ៉ាន់។

បន្ទាប់មកទៀត រូបភាពទី ១១ រូបភាពទី ១១ ដោយសារតែកម្ទេចអំបែងរបស់ចាននោះ វាតូចៗ វាតូចៗ និងពេលខ្លះគាត់ខ្លាចគាត់ប្រមូលមិនអស់ នឹងអាចធ្វើឲ្យគាត់មុតជើង ឬមានរបួស អញ្ចឹងគាត់ត្រូវ គាត់ត្រូវ គាត់ត្រូវប្រើម៉ាស៊ីនបូម ម៉ាស៊ីនបូមធូលី ដើម្បីបូមកម្ទេចទាំងអស់នោះ ដើម្បីការពារកុំឲ្យគាត់ដើរមុតជើង ឬក៏ការពារកុំឲ្យគាត់ដើរមាន[របួស] កុំឲ្យគាត់ នៅពេលដែលគាត់ដើរកម្ទេចនោះអាចធ្វើឲ្យគាត់ អាចធ្វើឲ្យគាត់មានរបួសបាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់បានដោត អញ្ចឹងគាត់បានដោត គាត់បានដោតខ្ញុយ គាត់បានដោតខ្ញុយ គាត់បានដោត គាត់បានដោតខ្ញុយម៉ាស៊ីនបូមធូលីនោះទៅនឹង ទៅនឹងរន្ធភ្លើងនៅជាប់នឹងជញ្ជាំង បន្ទាប់មកទៀតគាត់ក៏បានអូសប្រដាប់ ប្រដាប់បូមធូលីនោះចេញមកខាងក្រៅ ចេញចូលទៅក្នុងផ្ទះបាយ ដើម្បីបូមកម្ទេចនោះ។ ដោយសារតែម៉ាស៊ីនបូមធូលីនោះមានខ្សែភ្លើង មានខ្សែភ្លើងវែង ដូច្នេះគាត់អាចទាញម៉ាស៊ីននោះទៅឆ្ងាយ ទៅឆ្ងាយបន្តិចបាន ទៅឆ្ងាយបន្តិចបាន ដោយសារតែខ្សែភ្លើងរបស់ម៉ាស៊ីននោះគឺវែង។ អញ្ចឹងគាត់បានកាន់ គាត់បានកាន់ក្បាលសម្រាប់បូម បូមកម្ទេចនោះ និងបានអូសម៉ាស៊ីននោះតម្រង់ទៅកាន់បន្ទប់ តម្រង់ទៅកាន់ផ្ទះបាយរបស់គាត់ ដើម្បីបូមយកកម្ទេចចានដែលបានបែកនោះ។

រូបភាពទី ១២ រូបភាពទី ១២ នៅពេលដែលគាត់ដោតខ្ញុយភ្លើងជាប់ទៅនឹងរន្ធភ្លើង នៅជាប់នឹងជញ្ជាំង ម៉ាស៊ីននោះក៏អាចដំណើរការបូមយកកម្ទេច កម្ទេចចានដែលបានបែកជាកម្ទេចតូចៗ ដែលពេលខ្លះយើងពិបាកនឹងមើលឃើញ ដោយសារតែវាជាកម្ទេចតូចៗ និងពេលខ្លះពណ៌របស់វាស្រដៀងទៅនឹងឥដ្ឋ ស្រដៀងទៅនឹងឥដ្ឋ អញ្ចឹងធ្វើឲ្យយើងពិបាក ពិបាកមើលដោយប្រើ ដោយការប្រើភ្នែក និងអញ្ចឹងយើងត្រូវ ដើម្បីឲ្យប្រាកដថា មិនមានអំបែងនៅលើឥដ្ឋទៀតទេ អញ្ចឹងយើងត្រូវប្រើម៉ាស៊ីនបូមធូលី ដើម្បីបូមយកអំបែងនោះចូលទៅខាងក្នុង និងដើម្បីឲ្យ និងដើម្បីឲ្យប្រាកដថានៅលើឥដ្ឋគឺស្អាត មិនមានអំបែងទៀតទេ។ ម៉ាស៊ីនបូមធូលី គឺវាមានខ្យល់ខ្លាំង នៅពេលដែលយើងបើកម៉ាស៊ីន វានឹងបូមយកកម្ទេច និងរបស់ល្អិតៗតូចៗបានយ៉ាងងាយស្រួល ដោយសារតែខ្យល់របស់វាខ្លាំង និងវាអាចបូមយកធូលីដី ធូលីដី កម្ទេចតូចៗជាច្រើនបានយ៉ាងងាយស្រួល។

រូបភាពទី ១៣ ក្រោយពេលដែលគាត់បានប្រើម៉ាស៊ីនបូមធូលីនោះបូមយកកម្ទេចចាន ឬក៏អំបែងចាន ដែលបានជ្រុះធ្លាក់ចុះទៅលើ ជ្រុះធ្លាក់ទៅលើឥដ្ឋ ដោយគាត់មិនបាន ដោយគាត់មិនបានប្រុងប្រយ័ត្ននោះ អញ្ចឹងបាន អញ្ចឹងគាត់ក៏បានបូមយក អញ្ចឹងគាត់ក៏បានបូមយកកម្ទេចនោះ កម្ទេចនោះ ចូលទៅក្នុងម៉ាស៊ីនបូមធូលី។ អញ្ចឹងនៅលើឥដ្ឋរបស់គាត់គឺមិនមានកម្ទេច គឺមិនមានកម្ទេចចានដែលបែកនោះទៀតទេ។ អញ្ចឹងគាត់អាច បើសិនបើគាត់ដើរដោះស្បែកជើង អញ្ចឹងវាមិនអាចមុតជើងរបស់គាត់ទេ ដោយសារតែគាត់បានប្រើអំបោស បោសវាជាលើកទីមួយ បន្ទាប់មកគាត់ប្រើម៉ាស៊ីនបូមធូលីជាលើកទីពីរ ដើម្បីឲ្យច្បាស់ថា មិនមានកម្ទេច មិនមានកម្ទេចនៅលើឥដ្ឋទៀតទេ។ អញ្ចឹងក្រោយពេលដែលគាត់បូមរួចរាល់ហើយ គាត់ក៏បានយកម៉ាស៊ីននោះដាក់ចូលទៅក្នុងបន្ទប់ ដាក់ទៅកន្លែងដើមវិញ ដាក់នៅក្នុងបន្ទប់សម្រាប់ដាក់អីវ៉ាន់វិញ អញ្ចឹងគាត់បានអូសម៉ាស៊ីននេះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ម៉ាស៊ីននោះចូលមកក្នុងបន្ទប់ អញ្ចឹងគាត់បានរៀបចំម៉ាស៊ីននោះដាក់ទៅតាមកន្លែងវិញ និងបានដោះខ្ទុយនោះចេញពីប្រហោងភ្លើងដែលដាក់ជាប់នឹងជញ្ជាំង ដែលដាក់ជាប់នឹងជញ្ជាំង។

បន្ទាប់មកទៀតគាត់ក៏បានដើរទៅទូចាន ដើរទៅទូចាន ដែលទូចានយើង ទូចានគឺ គឺទូចានរបស់គាត់គឺដាក់នៅជាប់នឹងជញ្ជាំង ដែលទូចានគឺយើងប្រើសម្រាប់ដាក់ចាន ដាក់ស្លាបព្រា ដាក់កាំបិតនៅក្នុងនោះ ដើម្បីកុំឲ្យមានធូលីដី ឬក៏ដើម្បី ដើម្បីការពារ នៅពេលដែលយើងយកចានមកប្រើច្រើនពេក អញ្ចឹងវាអាចធ្វើឲ្យចាននោះងាយស្រួលបែក ងាយស្រួលបែក អញ្ចឹងយើងត្រូវដាក់ ប្រសិនបើយើងដាក់នៅលើទូឆ្ងាយពីដៃ គឺអាចមានសុវត្ថិភាព មិន មិនបែកទេ ប្រសិនបើយើង ប្រសិនបើយើងត្រូវការប្រើ យើងគ្រាន់តែបើកទូនោះ និងយកចាននោះមកជាការស្រេច អញ្ចឹងងាយស្រួល អញ្ចឹងប្រសិនបើយើង ប្រសិនបើយើងដាក់វានៅខាងក្រោម នៅពេលដែលយើងធ្វើម្ហូប យើងអាចធ្វើឲ្យបែកចាននោះបានយ៉ាងងាយស្រួល។ អញ្ចឹង អញ្ចឹងជាទូទៅ នៅពេលដែលយើងលាងសម្អាតចានហើយ ឬក៏ចានខ្លះដែលយើងមិនសូវប្រើប្រាស់ មិនសូវប្រើប្រាស់ គឺយើងភាគច្រើនគឺយើងយកទៅទុកនៅក្នុង នៅក្នុងទូចាន ដោយយើងឃើញទូចានរបស់គាត់មានពីរថ្នាក់។ នៅខាង នៅខាងលើដាក់ចានសម្ល ឬក៏ចានគោមពណ៌ស នៅខាងក្រោមគឺដាក់ចានសម្ល និងចានគោមដូចគ្នាប៉ុន្តែមានពណ៌បៃតង មានពណ៌បៃតង។ ដោយនៅខាងក្រោមនោះ យើងឃើញមានឡាបូសម្រាប់លាងដៃ ឬក៏ជាកន្លែងសម្រាប់លាងចាន មានន័យថា នៅពេលដែលយើងធ្វើម្ហូប នៅពេលដែលយើងញ៉ាំបាយហើយ ចានរបស់យើងនឹងប្រឡាក់ ដូច្នេះយើងអាចយកចានរបស់យើងមកលាងនៅកន្លែងនេះ ដែលយើងមានថាសសម្រាប់ ដែលយើងមានថាសសម្រាប់ សម្រាប់ដាក់ទឹក សម្រាប់ដាក់ទឹកចូលដើម្បីលាង និងមានទុយោបង្ហូរទឹកចូលទៅខាងក្រោម និងមានក្បាលម៉ាស៊ីនសម្រាប់បើកឲ្យទឹក សម្រាប់បើកដើម្បីប្រើប្រាស់ទឹកនោះបាន។ និងនៅសងខាងនោះយើងឃើញដូចជាមាន មានកែវទឹក ឬក៏ជាមាន ដូចជាមានដបដែលដាក់នៅសងខាងក្បាលម៉ាស៊ីនទឹកនោះ។ អញ្ចឹងគាត់ នៅពេលដែល នៅក្រោយពេលដែលគាត់ធ្វើឲ្យបែកចាន បែកចានគោម ឬក៏ចានសម្លដែលមានពណ៌ក្រហមនោះ អញ្ចឹងគាត់ក៏បានដើរមកបើកទូចាន ដើម្បីយកចានមួយទៀត ដើម្បីយកចានមួយទៀត ទៅជំនួសចានដែលគាត់បានធ្វើបែកនោះ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ ក្រោយពេលដែលគាត់បើកទូ និងយកចានគោម ឬក៏ចានសម្លពណ៌បៃតងនោះ ចេញពីក្នុងទូ គាត់ក៏បាន គាត់ក៏បានលាងសម្អាតចាននោះឲ្យស្អាតម្តងទៀត បន្ទាប់មក គាត់ក៏បានដាក់ចាននោះនៅលើតុ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ក្បែរនឹង ក្បែរនឹងបន្លែ ក្បែរនឹងបន្លែរបស់គាត់ ប៉ុន្តែលើកនេះគឺគាត់ដាក់ឆ្ងាយពីដៃរបស់គាត់ ពីព្រោះកុំឲ្យមានរឿងកើតឡើងដូចជាពេលមុនទៀត។ អញ្ចឹងគាត់ដាក់ គាត់ដាក់ចាននោះនៅខាងស្តាំដៃរបស់[គាត់] នៅខាងឆ្វេងដៃរបស់គាត់ក្បែរបន្លែ ដែលមានដូចជា ខ្ទឹមបារាំង ប៉េងប៉ោះ ខ្ទឹមបារាំងប៉េងប៉ោះ និងការ៉ុត និងយើងឃើញ និងយើងឃើញមានកាំបិត និងមានដុំការ៉ុតតូចៗ ដែលគាត់ប្រើកាំបិតនោះចិតវា ដើម្បីធ្វើជាសម្ល ឬក៏ស៊ុប។ អញ្ចឹងគាត់បានដាក់ចាននោះនៅក្បែរនឹងបន្លែទាំងអស់នោះ។ បន្ទាប់មកទៀតគាត់ក៏បានបន្ត គាត់ក៏បានបន្ត គាត់ក៏បានបន្តហាន់ គាត់ក៏បានបន្តចិតបន្លែរបស់គាត់បន្តទៀត ក្រោយពេលដែលគាត់ធ្វើឲ្យបែកចាន និងក្រោយពេលដែលគាត់សម្អាតនូវកម្ទេចចានដែលគាត់ធ្វើឲ្យបែកនោះរួចរាល់ហើយ អញ្ចឹងគាត់ក៏បានចូលមកក្នុងចង្ក្រានបាយនិងធ្វើ និងធ្វើម្ហូបបន្តទៀត។ នៅពេលនេះគឺគាត់ដាក់ចានគោមថ្មីនៅឆ្ងាយពីដៃរបស់គាត់ អញ្ចឹងលើកនេះគឺចានគោមនោះមិនបែកទៀតទេ អញ្ចឹងបើទោះបីជាគាត់ហាន់បន្លែខ្លាំងៗ ចាននោះក៏មិនធ្លាក់បែកដែរ ដោយសារតែគាត់ដាក់នៅឆ្ងាយពីដៃរបស់គាត់ ដោយគាត់ដាក់នៅក្បែរបន្លែ ដាក់នៅក្បែរបន្លែខាងស្តាំ ខាងឆ្វេងដៃរបស់គាត់។ អញ្ចឹងលើកនេះគាត់អាច គាត់អាចបន្តធ្វើសម្លឬក៏ស៊ុបសម្រាប់អាហារ សម្រាប់អាហាររបស់គាត់នៅថ្ងៃនេះ ដោយយើងឃើញគាត់ហាន់ការ៉ុតជាដុំតូចៗ នៅពេលដែលគាត់ចម្អិនម្ហូបរួចហើយ គាត់នឹងដួសម្ហូបនោះដាក់ចូលទៅក្នុងចានគោម ដាក់ចូលទៅក្នុងចានគោម ឬក៏ចានសម្ល ដែលគាត់ទើបនឹងយកចេញពីក្នុង ពីក្នុងទូចានរបស់គាត់នៅក្នុង នៅក្នុងចង្ក្រានបាយ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.